## ANNEX 2 C –ADDITIONAL OCP DOCUMENTS RELATING TO TUOL PO CHREY EXECUTION SITE
## OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN

002/19-09-2007-ECCC/TC

**ទីពិឃាតទួលពោធិ៍ជ្រៃ**

| ល.រ | លេខឯកសារ | E9/31 | ប្រភេទ | អ្នកនិពន្ធ | កាលបរិច្ឆេទ | ចំណងជើង | ERN ភាសាខ្មែរ | ERN ភាសាអង់គ្លេស | ERN ភាសាបារាំង | ការពិពណ៌នា | ចំណុចនៃការចោទប្រកាន់ |
|---|---|---|---|---|---|---|---|---|---|---|---|
| ១ | **IS 18.78** | E9/31.19 (ឧបសម្ព័ន្ធ ១៩) លេខ៤១ | របាយការណ៍វិភាគ | ស៊ិន ឃិន | ២៣ ឧសភា ១៩៩៧ | របាយការណ៍វិភាគរបស់មជ្ឈមណ្ឌលឯកសារកម្ពុជា មានចំណងជើងថា "ទម្រង់របាយការណ៍ទីតាំងលេខ 150201" | 00292775-00292775 | 00068300-00068300 | 00762094-00762102, 00810572-00810572 | រៀបរាប់អំពីទីតាំងគុក និងទីតាំងកប់សាកសពនៅទួលពោធិ៍ជ្រៃ | **ទីពិឃាត ទួលពោធិ៍ជ្រៃ [175: 698 ដល់ 714]** |
| | **មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**<br><br>ឯកសារត្រូវបានរៀបចំឡើងក្រៅក្របខណ្ឌតុលាការ។ ការកំណត់ទីតាំងនៃទីកន្លែងប្រព្រឹត្តឧក្រិដ្ឋកម្មទួលពោធិ៍ជ្រៃ ដោយផ្អែកលើចម្លើយសាក្សីម្នាក់រាង « ធាត់ » និង « មានកំពស់ 1m65 »។ | | | | | | | | | | |
| ២ | **D313/1.2.104** | E9/31.15 (ឧបសម្ព័ន្ធ ១៥) លេខ៥៤៦ | រូបថត | ETCHESON Craig | ??-??-១៩៩៧ | រូបថតបង្ហាញពីកន្លែងសម្លាប់មនុស្សទួលពោធិ៍ជ្រៃ | គ្មាន | P 00398572-00398572 | គ្មាន | រូបថត ថតដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញពីសាក្សី សេង ឈន នៅទីតាំងរណ្តៅសាកសពរួម នៅ ទួលពោធិ៍ជ្រៃ តំបន់៧ ភូមិភាគពាយ័ព្យ ថតនៅប្រហែលជាឆ្នាំ ១៩៩៧។ | **ទីពិឃាត ទួលពោធិ៍ជ្រៃ [175: 698 ដល់ 714]** |
| | **ពុំមានភាពសមហេតុសមផល**<br>រូបថតសាក្សីដែលមានរូបរាង« ធាត់ » នៅក្នុងឯកសារមុន។ | | | | | | | | | | |
| ៣ | **D313/1.2.106** | E9/31.15 (ឧបសម្ព័ន្ធ ១៥) លេខ៥៤៧ | រូបថត | ETCHESON Craig | ??-??-១៩៩៧ | រូបថតបង្ហាញពីរណ្តៅសាកសពរួមនៅទួលពោធិ៍ជ្រៃ | គ្មាន | P 00398571-00398571 | គ្មាន | រូបថត ថតដោយ មជ្ឈមណ្ឌលឯកសារកម្ពុជា បង្ហាញពីសាក្សី ហែម ជា (HEM Chea) នៅទីតាំងរណ្តៅសាកសពរួម នៅ ទួលពោធិ៍ជ្រៃ តំបន់៧ ភូមិភាគពាយ័ព្យ ថតនៅប្រហែលជាឆ្នាំ១៩៩៧។ | **ទីពិឃាត ទួលពោធិ៍ជ្រៃ [175: 698 ដល់ 714]** |
| | **មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**<br>ឯកសារពី ១ ដល់ ៣ មានរូបថតពីរ និងរបាយការណ៍របស់មជ្ឈមណ្ឌលឯកសារកម្ពុជាដែលមានលក្ខណៈមិនច្បាស់លាស់ មិនអាចបង្ហាញថាអត្ថបទនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។ | | | | | | | | | | |

**ANNEX 2 C –ADDITIONAL OCP DOCUMENTS RELATING TO TUOL PO CHREY EXECUTION SITE**
**OBSERVATIONS DE L'EQUIPE DE DEFENSE DE M. KHIEU SAMPHAN**

002/19-09-2007-ECCC/TC

**ទីពិឃាតទួលពោធិ៍ជ្រៃ**

| ល.រ | លេខឯកសារ | E9/31 | ប្រភេទ | អ្នកនិពន្ធ | កាលបរិច្ឆេទ | ចំណងជើង | ERN ភាសាខ្មែរ | ERN ភាសាអង់គ្លេស | ERN ភាសាបារាំង | ការពិពណ៌នា | ចំណុចនៃការចោទប្រកាន់ |
|---|---|---|---|---|---|---|---|---|---|---|---|
| ៤ | **D125/194** | E9/31.20 (ឧបសម្ព័ន្ធ ២០) លេខ៦០ | ដីកាចាត់ឲ្យស៊ើបសួរជំនួស | ECCC-OCIJ | ១៩ មិថុនា ២០០៨ | របាយការណ៍អនុវត្តដីកាចាត់ឲ្យស៊ើបសួរជំនួស | 00198174-00198182 | 00375363-00375370 | 00486017-00486025 | រៀបរាប់អំពីបេសកកម្មស្តាប់ចម្លើយសាក្សី អ៊ុក សារុធ ហៅ ញ៉ៅ, ស៊ុយ សេងឈន និង ស៊ុម អាឡាត់ ហៅ ឆុងឡាត់ ទាក់ទងនឹងបញ្ហាមួយចំនួន រួមទាំងកន្លែងសម្លាប់មនុស្ស ទួលពោធិ៍ជ្រៃ | **ទីពិឃាត ទួលពោធិ៍ជ្រៃ [175: 698 ដល់ 714]** |

**មានលក្ខណៈច្រំដែល**

**មិនអាចបង្ហាញថាឯកសារនោះចង់លើកឡើងអំពីបញ្ហាអ្វីនោះទេ។**

គឺជារបាយការណ៍នៃការបិទកិច្ចស៊ើបសួរជំនួសរបស់អ្នកស៊ើបអង្កេតម្នាក់របស់សហចៅក្រមស៊ើបអង្កេត។ ឯកសារបានសង្ខេបសក្ខីកម្មដែលផ្ដល់ដោយសាក្សីនានាដែលគាត់បានធ្វើការសម្ភាស។ អ្នកស៊ើបអង្កេតបាន បញ្ជាក់ថាគាត់បានភ្ជាប់ជា មួយ របាយការណ៍នេះ នូវកំណត់ហេតុស្ដាប់យកចម្លើយ ព្រមទាំងឯកសារថតសម្លេងនៃការស្ដាប់យកចម្លើយផងដែរ។ ក្នុងរបាយការណ៍ មានអត្ថបទសង្ខេបសក្ខីកម្មនានាដែលផ្ដល់ដោយសាក្សី។ ឯកសារនេះមានលក្ខណៈច្រំដែល ដោយហេតុថាកំណត់ហេតុសួរយកចម្លើយសាក្សីទាំងនេះ ព្រមទាំងឯកសារថតសម្លេងកិច្ចសម្ភាសទាំងនេះមាននៅក្នុងសំណុំរឿងរួចទៅហើយ មិនតែប៉ុណ្ណោះ សហព្រះរាជអាជ្ញាមានបំណងចង់ប្រើប្រាស់ឯកសារទាំងនេះធ្វើជាឯកសារភ័ស្ដុតាង និង/ឬ សាក្សីត្រូវបានគេកោះហៅឲ្យមកផ្ដល់សក្ខីកម្មនៅ ចំពោះមុខអង្គជំនុំជម្រះ។ បើទោះជារបាយការណ៍មិនបានបញ្ជាក់ឲ្យបានច្បាស់ក៏ដោយ ដូចគ្នាទៅនឹងឯកសារលេខ D125/217 ដែរ "មធ្យោបាយភ័ស្ដុតាងតែមួយគត់ដែលច្បាប់ទទួលស្គាល់ គឺអត្ថបទដើមនៃកំណត់ហេតុស្ដាប់យកចម្លើយចុះហត្ថលេខាដោយសាក្សីដូចដែលបានបញ្ជាក់នៅក្នុងបរិបទនេះ។